**BMI0013**

# សម្ភាសន៍ជាមួយ គង់ ជីនី ភេទស្រី អាយុ៥៣ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កម្មករ

## មុខរបរសព្វថ្ងៃៈ មេភូមិត្រសេកជ្រុំ

## ស្រុកកំណើតនៅភូមិរការលើ ឃុំថ្កូក ស្រុកស្ទោង ខេត្តកណ្តាល

## រស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឆាយ ឈុនលី

## ០០:៣០:១២ និង ០០:៥០:០៩

## ២៦ទំព័រ

ឈុនលីៈ ខ្ញុំឈ្មោះឈុនលី ខ្ញុំចង់ដឹងឈ្មោះមីងតើមីងឈ្មោះអី រស់នៅភូមិអី ហើយមានតួនាទីអី?

ជីនី ៈ ឈ្មោះគង់ ជីនី ។

ឈុនលីៈ អាយុប៉ុន្មានហើយមីង?

ជីនី ៈ អាយុ៥៣ឆ្នាំ ។

ឈុនលីៈ នៅទីនេះគេហៅភូមិអីគេមីង?

ជីនី ៈ ភូមិត្រសេកជ្រុំ ។

ឈុនលីៈ មីងរស់នៅទីនេះយូហើយ?

ជីនី ៈ ខ្ញុំមកនៅទីនេះតាំងពីឆ្នាំ៧៩ រត់ពីនោះមកតាំងពី៧៩ កាលពីមុនខ្ញុំនៅធ្វើការនៅរោងចក្រព្រែកព្នៅ តំឡើងកាណូត-កប៉ាល់ ក្រោយមកអង្គការជម្លៀសមកថាមួយរយៈទេ មកនៅកំពង់ឆ្នាំង តែដល់ពេលនេះទៅមិននៅកំពង់ឆ្នាំងមកនៅដល់ព្រំដែនយើងនេះ ។

ឈុនលីៈ ពេលមកនៅហ្នឹងយ៉ាងម៉េចទៅមីង?

ជីនី ៈ កាលនោះមករត់ប្រដាប់ប្រភឹង យើងនឹកថាអង្គការជម្លៀសយើងមកនេះនឹងរកសេចក្តីសុខឲ្យយើង តែដល់ពេលមកដល់យើងនាំគ្នារត់ប្រដាប់ប្រភឹង យើងនៅទីនេះស្លាប់ច្រើនណាស់អ្នកគ្រូអើយ អត់ មានបាយទឹកហូប ហើយយើងដាច់ខ្សែរយៈជាមួយពកម៉ែហើយ បានមកនៅព្រំដែននេះអង្គការ

បានទំនាក់ទំនងបានបើកអង្គរបានហូប សំភារៈអីឲ្យហូបបានគ្រប់គ្រាន់ ។ យើងកាលមួយរយៈដាច់ ពោះស្លាប់ច្រើនណាស់គេដើងគ្មានអត់មានអីហូបកាលរឹក៧៩ ថ្នាំពេទ្យក៏គ្មាន បាយក៏គ្មាន បើកឲ្យដែរ អង្គរមួយកំប៉ុងគ្នា៦នាក់ហូប បបរលាយជាមួយស្លឹកឈើ ស្លឹកដំឡូង ត្រពាំង មើមដំឡូងមើមអី ចេះតែនាំគ្នាហូបទៅដើម្បីចិញ្ចឹមជីវិតទំរាំតែថ្នាក់ដឹកនាំយើងទាក់ទងគ្នាបាន បានគេបើកអង្គរ ត្រី សាច់ បន្លែហូបបាន កាលនោះទៅនៅជំរុំស្រះកែវ ។

ឈុនលីៈ ចុះពេលមីងមកនៅដំបូងស្ថានភាពទីនេះយ៉ាងម៉េចដែរ?

ជីនី ៈ មកមុនដំបូងព្រៃសុទ្ធ នៅក្នុងព្រៃរនាម ព្រៃរឹរ ព្រៃខ្លានៅ ។

ឈុនលីៈ ចឹងកាលនៅមានមនុស្សមកច្រើន?

ជីនី ៈ ច្រើន ច្រើនណាស់តែស្លាប់អស់ច្រើននាក់ណាស់ ។

ឈុនលីៈ ស្លាប់ដោយសារអីដែរមីង?

ជីនី ៈ ស្លាប់ដោយសារគ្រុនចាញ់ ។

ឈុនលីៈ ហ្អ! ចឹងនៅទីនេះជាតំបន់គ្រុនចាញ់?

ជីនី ៈ ចាញ់ ពីមុនចាញ់ណាស់ ងាប់អស់មិនចេះតិចប្រជាជនស្លាប់អស់ច្រើនណាស់ សូម្បីតែនារីដឹក ជញ្ជូន ។

ឈុនលីៈ ចឹងពេលមកហ្នឹងអាចប៉ាន់ប្រមាណចំនួនបានទេ?

ជីនី ៈ មកពីមុនមក?

ឈុនលីៈ ចា៎!

ជីនី ៈ ច្រើនណាស់ គ្រប់អង្គភាពតែឥឡូវវាបែកសាខាអស់ហើយ ងាកទៅអង្គភាពនេះ អង្គភាពនោះ បែកចែកជាភូមិ ឃុំ គ្រាន់តែក្នុងឃុំខ្ញុំមិនចេះតិចគ្រួសារ ពាន់ជាង ។

ឈុនលីៈ ចុះពេលមកដល់ចឹងស្បៀងអីយ៉ាងម៉េចវិញ?

ជីនី ៈ ស្បៀងអាហារកាលពីមុនអង្គការគេចែកឲ្យយើង តែឥឡូវអង្គការគេឈប់ចែកឲ្យយើងចឹងយើងឯក រាជ្យម្ចាស់ការដោយរៀងៗក្រុមគ្រួសារ ពីមុនអង្គការខបត្ថម្ភឲ្យយើង ។

ឈុនលីៈ អង្គការអីគេ?

ជីនី ៈ អង្គការរួម អង្គការពិភពលោកជួយផ្តល់អាហារគ្រប់តាំងពីថៃ ។

ឈុនលីៈ កាកបាទក្រហមហ្អីមីង?

ជីនី  :  ចា៎! រួមទាំងកាកបាទក្រហមដែរ ។

ឈុនលីៈ  ទីស្នាក់ការគេនៅឯណាមីង?

ជីនី  :  អង្គការពិភពលោកមកពីគ្រប់ប្រទេស
មិនដឹងប្រទេសណាខ្លះមកជុំគ្នាបែងចែកតាមស្ថាប័នរៀងៗ ខ្លួន ។

ឈុនលីៈ  ចុះកាលនោះមីងមានអ្នកណាខ្លះជាសាច់ញាតិមកជាមួយ?

ជីនី  :  ពីដំបូងមានតែពីរនាក់ប្ដីប្រពន្ធទេ ឥឡូវមានកូនមានចៅហើយ កូនបានរៀនថ្នាក់ទី៩ ថ្នាក់ទី១២ ទៅប្រឡងថ្នាក់ទី១២ហើយបានចូលរៀនជានិស្សិតនៅភ្នំពេញបានឆ្នាំទីបីហើយ ។

ឈុនលីៈ  បង់លុយដែរអត់មីង?

ជីនី  :  បង់

ឈុនលីៈ  រៀនផ្នែកអីគេមីង?

ជីនី  :  ផ្នែកកសិកម្ម កាលមុនវាមកបេះស្លឹកឈើយកទៅពិសោធន៍ ។

ឈុនលីៈ  ប្រុសហ្នឹមីង?

ជីនី  :  ស្រី ។

ឈុនលីៈ  នៅសាលាណាមីង?

ជីនី  :  រៀននៅឯណាទេ

ឈុនលីៈ  នៅភូមិន្ទ?

ជីនី  :  ភូមិន្ទភ្នំពេញ ។

ឈុនលីៈ  មីងបើចាញ់អីចឹងមានវិធីអីព្យាបាលទេ?

ជីនី  :  មានអ្នកគ្រូ ឥឡូវយើងមានមន្ទីរពេទ្យព្យាបាលទាំងគ្រូនចាញ់ អ្នកពោះធំអីសព្វគ្រប់ហើយ ។

ឈុនលីៈ  មីងថាមកទាំងអង្គភាពចឹងម៉េចទៅ?

ជីនី  :  អង្គភាពពីដំបូងហៅថា១១៦ នៅត្រសេកជ្រុំ ។

ឈុនលីៈ  ម៉េចទៀតទៅមីង?

ជីនី  :  អង្គភាពគេចែកជាក្រុម ជាកង ជាពួកចឹងទៅ ។

ឈុនលីៈ  ចឹងពេលមកនៅហ្នឹងគេចែកជាអង្គភាពចឹងហ្អី?

ជីនី  :  ចា៎! ចែកជាអង្គភាព ។

ឈុនលីៈ  កាលនោះអ្នកណាគេដឹកនាំអង្គភាព មីង?

ជីនី ៖ ខាងកងទ័ពកាលពីមុន គេហៅ១១២ ប៉ុន្មានទេពេលគេត្រួសត្រាយផ្លូវ ពួកខ្ញុំស្លាប់យុទ្ធជនអស់ ច្រើនដែរ ពួកខ្ញុំចេញចេះទៅ ហើយខាងទាហានខ្មែរដាក់មីនមួយសារទៀត ដល់ពេលពួកខ្ញុំចូល មកស្លាប់មនុស្សអស់មិនចេះតិចទំរាំតែបានមកកកើតនៅភូមិនេះ គេជម្លៀសពួកខ្ញុំទៅនៅដលជិរ៉ុ ៥-៨៥ (ខ-៨៥) ។

ឈុនលី៖ អ្នកណាអ្នកដាក់មីន មីង?

ជីនី ៖ យួនចូលមកជាមួយទាហានខ្មែរ ។ ពួមុនយើងនេះគេហៅថាទាហានខ្មែរក្រហម គេឯណោះទាហាន ប៉ុន្តែគេត្រូវជាមួយយួន ដល់ពេលមកគេដាក់មីនក្រាលពេញផ្លូវ យើងមកនៅត្រួសត្រាយផ្លូវខ្លួន ឯងជីកចប បន្តិរខ្លួនឯងទៅណាស ដើម្បីរកប្រឡោះនៅខ្លួនឯង ។

ឈុនលី៖ អ្ហ៎! ធ្វើខ្លួនឯងចឹង?

ជីនី ៖ ចា៎! តែឥឡូវយើងមានកងស៊ីម៉ាក់ហើយ ។

ឈុនលី៖ ធ្វើយ៉ាងម៉េចទៅមីង ចឹងមិនមានគ្រោះថ្នាក់?

ជីនី ៖ ចូកប៉ែល អ្នកគ្រូ!អាចអ្នកខ្លះស្លាប់ដែរពេលប៉ះទៅផ្ទុះ ។

ឈុនលី៖ ចឹងធ្វើម៉េចទៅ?

ជីនី ៖ បើយើងមិនត្រួសត្រាយផ្លូវ យើងអត់មានកន្លែងនៅព្រោះយើងទៅនៅសំចតដីថៃ គេឲ្យយើងនៅ បានតែមួយរយៈទេ ដល់ពេលយើងមកនៅមាតុភូមិនិវត្តខ្លួនយើង យើងនៅម្ចាស់ការខ្លួនយើង ។ យើងឈូសឆាយកន្លែងនៅខ្លួនយើង ។ មុនដំបូងប្រក់ស្បូវផ្ទះខ្ទមតូចៗ តង់គេចែកឲ្យ ។

ឈុនលី៖ ហើយមានព្រៃចឹងយើងនៅក្នុងព្រៃចឹង?

ជីនី ៖ ចា៎! ព្រៃយើងកាប់ ។

ឈុនលី៖ ចឹងភូមិនេះសុទ្ធតែមីនទាំងអស់?

ជីនី ៖ ចា៎! សុទ្ធតែមីនទាំងអស់ ។ នេះខាងក្រោយសុទ្ធតែខ្សែក-៥ ទៅដល់នោះកន្លែងដែលគេដាក់មីន ទៅដល់អូរ ។

ឈុនលី៖ មីនចឹងគេដាក់ប៉ុន្មានម៉ែត្រមួយទៅ?

ជីនី ៖ គេរាយដាក់តាមតូចតាមធំ អាកំប៉ុង

ឈុនលី៖ គេដាក់រាងយ៉ាងម៉េចទៅមីង?

ជីនី ៖ គេដាក់តាមខ្សែ ។

ឈុនលី៖ ខ្សែត្រង់តែម្តងហ្អីមីង?

ជីនី ៖ ចាំ!

ឈុនលី៖ ហើយប៉ុន្មានដាក់មួយទៅ?

ជីនី ៖ ប្រហែល៥ម៉ែត្រអីហ្នឹងមានអាតូចអាធំ ។

ឈុនលី៖ ចឹងរហូតដល់ឥឡូវមីននៅតែមានទៀត?

ជីនី ៖ មានដែរតែវាសល់ចំនុចតូចៗ ។ ខ្ញុំធ្វើដំណើរឲ្យស៊ីម៉ាក់គេដោះដែរនោកន្លែងនោះបន្តិចទៀត ។ អ្នក នេះចង់ដោះអ្នកនោះចង់ដោះដណ្តើមគ្នា នៅសល់តែបន្តិចគេដាក់ចោលឈប់ដោះ ។ ខ្ញុំចេះតែធ្វើ ដំណើរតាំងពី២០០៥ ២០០៦ ២០០៧ ២០០៨ រហូតដល់២០១០នៅសល់តែបន្តិចអត់ ទាន់ហើយ ។

ឈុនលី៖ ចុះមីងថាអង្គការជួយចឹងមានអីគេខ្លះទៅ?

ជីនី ៖ គេឧបត្ថម្ភអង្ករ ត្រីខ អំបិល ប្រហុក ស្ករ ប៊ីចេង ទឹកដោះគោ មេ្សា ពងមាន់ ខ្ទាញ់ ។

ឈុនលី៖ តែមីងអត់ចាំថាកាកបាទក្រហមហ្នឹង ខាងណាទេហ្ន៎?

ជីនី ៖ អង្គការពិភពលោកគ្រប់ទាំងអស់ គេរួមសហការគ្នាជួយប្រជាពលរដ្ឋក្នុងស្រុកខ្មែរយើងនេះ ។

ឈុនលី៖ ដូចជាស្បៀងអាហារអី?

ជីនី ៖ ចាំ! ស្បៀងអាហារពិភពលោកតាំងពីថ្នាំពេទ្យអីហ្នឹង កុំអីមិនដឹងទៅណាអស់ទេពួកខ្ញុំនេះ ។ ខ្វង់ឆ្នាំ ៨៨-៨៩នេះឯង ដែលគេជម្លៀសខ្ញុំទៅនៅដីថៃ ព្រោះអីគ្រាប់ផ្លោងខ្លាំងពេកហើយគេអត់ឲ្យ គ្រួសារទ័ព នៅទីនេះទេ មានតែទ័ពទេដែលនៅការពារព្រំដែន ។

ឈុនលី៖ ចឹងមានន័យថាមានតែគ្រួសារទ័ពទេដែលជម្លៀសទៅ?

ជីនី ៖ ចាំ! ប្រពន្ធទៅនៅដីថៃ ប្តីនៅទីនេះ ។

ឈុនលី៖ ដីថៃហ្នឹងនៅឯណា?

ជីនី ៖ នៅ៨៥ ម៉ុំផ្លូវជាតិទី២ទី៣ ។

ឈុនលី៖ ៨៥ ជាតំបន់ឬយ៉ាងម៉េច?

ជីនី ៖ ជាតំបន់ គេហៅភូមិ៨៥ចឹង ។

ឈុនលី៖ មីងទៅឆ្នាំណា?

ជីនី ៖ ទៅពីឆ្នាំ៨៦ ។

ឈុនលីៈ ចុះពេលដែលមីងមកហ្នឹងមានមីនហើយនៅ?

ជីនី ៈ ពេលដែលពួកខ្ញុំចេញបានគេដាក់ ចេញទៅនៅដីថៃ ។

ឈុនលីៈ ចុះមីងមកនៅប៉ុន្មានឆ្នាំបានជម្លៀសទៅនៅថៃ?

ជីនី ៈ ប្រហែលមួយឆ្នាំ ពីរឆ្នាំ ។

ឈុនលីៈ ចឹងប្រហែលជាឆ្នាំ៨១-៨២ហើយ ។ ចឹងទៅនៅតំបន់៨៥ ឆ្ងាយទេមីង?

ជីនី ៈ ប្រហែលពីនេះទៅថ្នល់ជាតិទី១ ទី២ ទី៣៦ណោះ ។ គេយកយើងទៅដាក់នៅទីនោះស្រួលណាស់ អ្នកគ្រូហ្អ៊ឺយ នៅជិតចំការដំឡូងថៃ ។

ឈុនលីៈ តំបន់នោះម៉េចដែរមីង?

ជីនី ៈ ដីព្រៃដែរហ្នឹង ។

ឈុនលីៈ ហើយថៃហ្នឹងគេឲ្យយើងនៅដែរ?

ជីនី ៈ គេឲ្យយើងស្នាក់បាន ។

ឈុនលីៈ ហើយគេចែកអំណោយដែរអត់?

ជីនី ៈ ចែក ពេលទៅដល់ខាងកាកបាទក្រហមគេចែកឲ្យហើយ ។

ឈុនលីៈ ចឹងគេចែកនៅលើដីថៃទេ?

ជីនី ៈ ចាំ! ចែកនៅលើដីថៃ ហើយមិនថាតែខ្មែរទេប្រជាជនថៃក៏គេចែកឲ្យដែរ ។ ប្រជាជនថៃអត់ដូច តែយើងដែរនៅខ្ទមតូចៗ ហើយថៃក៏គេចូលរួមចែកដែរដើម្បីបានទាំងអស់គ្នា ។ ពេលយើងទៅ ដំបូងគ្រោះថ្នាក់ណាស់ មានពស់ច្រើនណាស់ តែពេលយើងនៅអត់ដែលមានអីទេដល់ពេលយើង ចេញមកវិញឮថាពួកថៃពស់ចឹកស្លាប់ច្រើនណាស់ ។ ដីខ្មែរ ខ្មែរត្រូវតែថែរក្សាខ្មែរ ។

ឈុនលីៈ ចឹងមានន័យថាយើងទៅហ្នឹងនៅលើទឹកដីខ្មែរទេ?

ជីនី ៈ ចាំ! ដីខ្មែរតាំងពីហ្នឹងដល់បាងកក តែថៃវាចេះតែចូលមក យើងសព្វថ្ងៃនេះកុំតែបានខ្មែរក្រហម ធ្វើជាឈ្មាន់ទេកុំអីមិនដឹងថៃចូលមកដល់ណាទេ កុំតែបានខ្មែរក្រហមមកនៅទេបានទឹកដីនៅគង់វង្ស បានបងប្អូនវិលមកវិញនៅនេះ ។

ឈុនលីៈ ចាំ! ចឹងមីងជម្លៀសពីណាមកនៅទីនេះ?

ជីនី ៈ ខ្ញុំជម្លៀសពីកំពង់ឆ្នាំងឡើងពីនោះមក ។

ឈុនលីៈ ចុះមីងកាលនោះធ្វើអីគេ?

ជីនី ៖ ខ្ញុំនៅរោងចក្រ កាលពីមុននៅខាងកសិកម្មក្រោយមកចេញមករោងចក្រ ។ មុនដំបូងនៅព្រែកព្នៅ តែអគ្គការថាឲ្យទៅនៅកំពង់ឆ្នាំងមួយអាទិត្យ តែមិនមែនមួយអាទិត្យនៅរហូតដល់ឥឡូវ ។

ឈុនលីៈ ចុះស្រុកកំណើតមីងនៅឯណា?

ជីនី ៖ នៅស្អាង ខាងក្រោមព្រែកតូច ។ នៅភូមិរការលើ ឃុំថ្កុក ស្រុកស្អាង ខេត្តកណ្ដាល មានឪពុក ម្ដាយនៅហ្នឹងតែឥឡូវពុកម្ដាយស្លាប់អស់ហើយនៅតែបងស្រីមួយទេ ។ ខ្ញុំដើរតួរតែម្នាក់ឯងដូចចក រសាត់ចឹងដំណើរការតស៊ូរបស់ខ្ញុំ ។

ឈុនលីៈ ចុះគ្រួសារមីងនៅស្រុកណាដែរ?

ជីនី ៖ គ្រួសារខ្ញុំធ្វើទ័ពនៅសំរោងក្អែនៅផ្លូវជាតិទីពីរ ទន្លេមេគង្គ ខេត្តកណ្ដាលដែរ ។ គាត់នៅកៀនស្វាយ ខ្ញុំនៅស្អាងជាប់គ្នា ។

ឈុនលីៈ កាលពីមុនគាត់ធ្វើទ័ពហើយ?

ជីនី ៖ កាលពីមុនគាត់នៅខាងកសិកម្មដល់គាត់ចេញពីកសិកម្មមកធ្វើទ័ពរហូត ។

ឈុនលីៈ ចុះមីងការជាមួយគាត់ឆ្នាំណា?

ជីនី ៖ ការនៅឆ្នាំយើងរត់ ៧៩ ។ ៧៨ ការហើយដល់៧៩រត់មកនេះតែម្ដង ។

ឈុនលីៈ ចុះកាលឆ្នាំ១៩៧៥ មីងនៅឯណា?

ជីនី ៖ ៧៥ ខ្ញុំនៅជំរុំតាង៉ុក ។

ឈុនលីៈ ៧៥ ពេលដែរខ្មែរក្រហមកាន់កាប់ដំបូងណាសមីង?

ជីនី ៖ អ៊ូ! ជំនាន់បីឆ្នាំខ្ញុំនៅខាងក្រសួងកសិកម្មនៅវត្តអង្គរជ័យ ខ្ញុំចាប់បានស្រែជិត១០០ហិចតានៅស្រុក កៀនស្វាយ ខ្ញុំចាប់បានស្រែ ។

ឈុនលីៈ អង្គរជ័យហ្នឹងភូមិឬក៏ឃុំ?

ជីនី ៖ គេហៅវត្តអង្គរជ័យ ភូមិជីឥដ្ឋ ផ្លូវជាតិលេខ១ ។

ឈុនលីៈ ធ្វើអីទៅមីង?

ជីនី ៖ ធ្វើស្រែ ខ្ញុំធ្វើដល់ឡុងបុិនអីណោះកាលខ្ញុំនៅតូចៗអាយុ១៥ ១៦ ទើបតែឥឡូវមកនៅទីនេះបាន យូរ ។

ឈុនលីៈ ចុះធ្វើស្រែក្នុងរបបនោះការហូបចុកម៉េចដែរ?

ជីនី ៖ ហូបចុកមុនដំបូកដាំឡាំងស៊ិន ហើយចែកគ្នាម្នាក់បន្តិច តែស្រូវមានមិនចេះតិចមិនដឹងយកទៅណា អស់ ។ ហូបបបរមុនដំបូង ក្រោយមកហូបនំប៉័ង ហើយបានហូបបាយ ។ ពួកខ្ញុំស្រីៗបាយមួយកំ ហូបឆ្អែតតែបើប្រុសៗហូបអត់ឆ្អែតទេ ។

ឈុនលី៖ កាលនោះអាយុប៉ុន្មានដែរមីង?

ជីនី ៖ កាលនោះអាយុ១៥ ១៦ឆ្នាំ បើកាលខ្ញុំចេញពីម្តាយខ្ញុំមកអាយុ១៥ ។ កាលនោះគេហៅថាក្នុង កងចល័ត នៅមន្ទីរ១៧ តែកាលនោះសប្បាយណាស់ ។ ពេលចេញមកនៅសល់ចប បង្គីអាឡោះ អាល័យណាស់ ព្រោះកាលនោះសប្បាយធ្វើការដេក ស្ទូងដល់ពេលយប់ម៉ោង៩បានចេញមក ។ មានអ្នកស្លាប់កាលនោះ ចុងភៅដើរទៅអត់ដឹកាន់កាំភ្លើងទៅមួយដើមអត់ដឹងចំរើបស្លាប ។ ខ្ញុំកាល នោះរិះលង់ទឹកស្លាប់ដែរហ្នឹង ដៃកាន់នឹម ស្បែកជើង និងកណ្តៀវម៉ោង៩កាលនោះយើងហូប បបរវាអស់កំលាំងព្រោះយើងងើបទៅធ្វើការតាំងពីម៉ោង៦ ម៉ោង៧ទៅការដ្ឋាន ។ គ្សិតតែអញ្ចឹង តែសប្បាយណាស់យើងធ្វើភោគផលបានច្រើន ។

ឈុនលី៖ ចុះតាំងពី៧៥ ៧៦ ៧៧ មកមីងនៅទីនោះរហូត?

ជីនី ៖ ចាំ! នៅទីនោះដល់៧៧ ៧៨ ទើបយើងឡើងមកនៅទីនេះ ។ ខ្ញុំមកហ្នឹងក្រោយគេហើយ ។

ឈុនលី៖ ចុង៧៨ ទេតើអ្ហីមីង?

ជីនី ៖ ចាំ!

ឈុនលី៖ គេប្រាប់ថាម៉េចកាលនោះ?

ជីនី ៖ គេថាឲ្យទៅស្នាក់នៅកំពង់ឆ្នាំងមួយរយៈសិន តែអត់មានយកអីមកទេឆ្នាំងចានអីទុកនៅកំពង់ឆ្នាំង នាំ គ្នាដើរ មកតាំងពីកំពង់ឆ្នាំងមួយយប់ទល់ភ្លឺបានដល់បាត់ដំបង ហើយមកស្នាក់នៅអំពិលប្រាំដើម ប្រជាជនសហករណ៍គេដាំបាយទទួល ។

ឈុនលី៖ ចុះម៉េចបានគេឲ្យចេញពីនោះមក?

ជីនី ៖ គេថាជម្លៀសចេញសិនព្រោះខាងខាងនោះច្បាំងគ្នាអត់មានកន្លែងជ្រក ជ្រកបណ្តោះអាសន្នទេណា តែដល់ពេលខ្ញុំមកនៅនេះនៅក្សួរប៉ឺងៗនៅឡើយ ។

ឈុនលី៖ កាលនោះវៀតណាមចូលហើយនៅ?

ជីនី ៖ ចូលមកហើយឆេះពីភ្នំពេញ ។ កាលនោះពួកខ្ញុំចេញមកក្រោយគេជិះកាណូត កប៉ាល់ល្អមើល ណាស់ថ្ងៃនោះ ។ អាម៉ិចទំលាក់គ្រាប់ផាប់មេកផខ្ញុំអស់មួយ ។

ឈុនលីៈ មេកផមីផកាលនោះឈ្មោះអី?

ជីនី ៖ ឈ្មោះតា រិន ។

ឈុនលីៈ ចុះមីផមាននៅសល់រូបថតពីដើមដែរអត់ ។

ជីនី ៖ រូបថតខ្ញុំចោលនៅអំពិលប្រាំដើមអស់ហើយកាលនោះមានរូបថតច្រើនកាលខ្ញុំនៅសិល្បៈ ។

ឈុនលីៈ អ្ហ៎! នៅសិល្បៈ?

ជីនី ៖ ខ្ញុំនៅសិល្បៈស្រុកដល់ក្រោយមកពួកតំបន់ គេទៅបង្រៀនខ្ញុំនៅសិល្បៈតំបន់ ចម្រៀងខ្ញុំច្រៀងនៅ ចាំដែរតើ ។ កាលនោះនាំគ្នារត់ប្រដាប់ប្រភីផភ័យផងអីផង នារីដឹកជញ្ជូនយើងស្លាប់នៅយើងនេះ ច្រើនណាស់ គ្រុនចាញ់ហើមពោះដូចកើតទាចទឹក ស្រីៗស្លាប់ច្រើន ជាពិសេសជនពិការខ្ញុំឃើញ ផ្ទាល់ភ្នែកកាលពី៧៩ នៅភ្នំដំរីពេលគេជម្លៀសទៅស្រះកែវ ហើយបើនៅស្រះកែវវិញខ្ញុំតាមដាន មួយថ្ងៃបីឡានទៅបួនឡានស្លាប់ ។ ហើយពេលទៅដំបូងគេបញ្ចុះទឹកដោះគេឲ្យយើងអស់ជាតិពុល ហើយបានគេឲ្យបាយចំណីរអីហូបដំបូងហ្នឹង គ្រពះម្នាក់ៗចង់ស៊ិតអស់ ហើយដល់ក្រោយមកមេ យើងបានសុំជំនួយពីអង្គការពិភពលោក ។ អ្នកខ្លះបានហូបហើយផ្អែកស្លាប់ក៏មានដែរ ។

ឈុនលីៈ ចុះមីផមានបងប្អូនដែលស្លាប់ដោយសារគ្រុនចាញ់ដែរទេ?

ជីនី ៖ មានតែអ្នកជិតខាង បើកូនខ្លួនឯងកាលនោះវាខ្លះឈាមបានអង្គការគេជួយ ។ កូនខ្ញុំកើតកាល៧៩ វាកើតនៅបឹងត្រកួន ។ កូនខ្ញុំមួយកើតនៅត្រាំងនៅប៉ៃលិនដល់ពេលមកវិញនៅទីនេះបានកូនមួយ ហើយទៅនៅស្រហកែវបានកូនមួយទៀតតែមកកើតនៅចំការចេកបឹងត្រកួនឆ្នាំ៨០ បន្ទាប់ទៀត ឆ្នាំកុរ ឆ្នាំឆ្លូវ ហើយខ្ញុំមានកូនចិញ្ចឹមមួយទៀតម្តាយស្លាប់បាត់ហើយឪពុកគេចាប់យកទៅឃុំ ឥឡូវបានដប់ឆ្នាំជាងហើយ ។

ឈុនលីៈ ខ្ញុំហាក់ដូចជាប្រឡំឆ្នាំ តាមពិតមីផការឆ្នាំ៧៨ទេ ហើយដល់៧៩បានមីផមានកូនមែនទេ?

ជីនី ៖ ចា៎! ការហើយបានពីរខែមកនៅនេះ ។ ខ្ញុំមកនៅធ្វើការរោងចក្រក៏វេទនាដែរ ដាំបាយលាយពោត កំបោរ ។

ឈុនលី៖ មីងថាធ្វើការរោងចក្រនៅឆ្នាំណាវិញ?

ជីនី ៖ នៅឆ្នាំ៧៥ ៧៦ រោងចក្រតំឡើងកាណូត កប៉ាល់ ។ គណៈក្រសួងខ្ញុំឈ្មោះ ភួន និងយាយសំ គាត់ស្លាប់អស់ហើយ ។

ឈុនលី៖ ចុះ តារិន?

ជីនី ៖ តារិន មេក្រុម ។

ឈុនលី៖ ហើយមួយក្រុមប៉ុន្មាននាក់ទៅ?

ជីនី ៖ គ្នាច្រើនដែរមិនចេះតិចស្រីផង ប្រុសផង ប្រហែល៣០០នាក់ ៦០០នាក់ដែរបើគេបែងចែក នៅក្រុមផ្សេងៗគ្នាដល់ពេលទៅធ្វើការបានជួបគ្នា ។ ខ្ញុំកាលនោះសន្ទប់ម្តងដែរអស់កម្លាំងពេកខ្យល់ គរ ។

ឈុនលី៖ ធ្វើការហ្នឹងហូបអីគេមីង?

ជីនី ៖ ហូបនំប៉័ងហើយដល់ពេលបាយគេចំហុយបាយលាយពោតឲ្យហូប បើកអង្ករបានដែរតើ ប៉ុន្តែលាយ ជាមួយពោតក្រហម ។

ឈុនលី៖ ចុះកាលនោះឪពុកម្តាយមីងធ្វើអីគេ?

ជីនី ៖ ឪពុកម្តាយខ្ញុំធ្វើស្រែចំការនៅផ្ទះ ។ ខ្ញុំចេញពីផ្ទះតាំងពីឆ្នាំ១៩៧១មក ។

ឈុនលី៖ ចេញមកដំបូងនៅឯណា?

ជីនី ៖ នៅសិល្បៈស្រុក ប្រហែល១៤ ១៥ឆ្នាំ ។

ឈុនលី៖ ចឹងមីងរៀនជាមួយគេ?

ជីនី ៖ ចេះតែតាមគេ កាលឆ្នាំ១៩៧០ហ្នឹងយួនចូលស្រុក ហើយនឹកឃើញថាតែយួនចូលមកហ្នឹងធ្វើ កូនៗហើយ ចឹងខ្ញុំក៏សុំម្តាយថា "ម៉ែអើយខ្ញុំសុំចេញពីម៉ែឯងទៅធ្វើការបដិវត្ត ហើយបើយើងមិនតស៊ូខ្លាចគេធ្វើបាបខ្មែរគ្នាយើង"

ខ្ញុំមានការឈឺចាប់បានខ្ញុំចូលហើយបងខ្ញុំក៏ចូលដែរតែគាត់ស្លាប់ បាត់ទៅហើយ ។ គាត់ធ្វើការខាងស្រុកសេដ្ឋកិច្ច ។

ឈុនលី៖ នៅខេត្តកណ្តាលអ្វី?

ជីនី ៖ ចា៎! តែគាត់ស្លាប់ហើយ ។ ប្អូនខ្ញុំធ្វើការនៅកងចល័តក៏ស្លាប់ដែរ ។

ឈុនលី៖ ចុះមីងថាសិល្បៈស្រុកហ្នឹងនៅខេត្តកណ្ដាល តើអ្វី?

ជីនី ៖ នៅខេត្តកណ្ដាល ស្រុកស្អាង ដល់ពេលចូលបដិវត្តិធ្វើកសិកម្ម ហើយចេញពីកសិកម្មខ្ញុំទៅនៅមន្ទីរ ម-១៧តំឡើងតួរកាណូត កប៉ាល់ ចេញពីហ្នឹងបានមកនៅទីនេះ ។ នៅនេះប្ដីធ្វើទ័ពហើយប្រពន្ធ ធ្វើការក្នុងភូមិ កូនៗអីក៏ឲ្យគ្នារៀនសូត្រចេះដឹងព្រោះឪពុកម្ដាយអត់ដែលបានរៀនទេ ។ កូនរៀនថ្នាក់ទី៩ខ្លះ ទី១២ខ្លះ ហើយខ្លះកំពុងតែរកការងារធ្វើក្រែងលបានខបត្ថម្ភខ្លួនទៅមុខទៀត ។

ឈុនលី៖ ចុះមីងរៀនបានថ្នាក់ទីប៉ុន្មាន?

ជីនី ៖ ខ្ញុំកាលនៅផ្ទះរៀនបានថ្នាក់ទី១០ តែរៀនៗរវល់តែឈប់ទៅមើលគោ ឃ្វាលគោ ភ្លេចណាស់ អ្នកគ្រូដល់ពេលធ្វើការខាងសិល្បៈ ហើយខ្ញុំមើលឡើងវិញឥឡូវធ្វើការផងបានចេះកាលពីមុនខ្ញុំ ងងឹតឈឹងអត់មានចាំទេ ។

ឈុនលី៖ ចុះមីងមានដឹងទេថាម៉េចបានគេជម្លៀសមកនៅតំបន់នេះ ម៉េចមិនទៅស្រុកកំណើតវិញ?

ជីនី ៖ ខ្ញុំនឹកឃើញថាស្រុកកំណើតម៉ែឪមានដីតិចពេក ចែកកូនមិនគ្រប់ ហើយបងប្អូនច្រើនខ្លះបានទទឹង៧ ម៉ែត្រ បណ្ដោយ៣០ម៉ែត្រនឹកឃើញថា វាតិចពេកខ្ញុំអត់ទៅវិញទៅនៅក្រាញនទាលទីនេះហើយ ម៉ែឪហៅទៅវិញដែរ តែមិនទៅងាប់រស់នៅព្រំដែននេះ ហើយសុខចិត្តស្លាប់នៅទីនេះ បើទៅលេង ខ្ញុំទៅចុះកាលពីមុនដីសុទ្ធតែធំៗម្នាក់៥០០មែត្រ ដល់គេយកអស់ហើយមានអីទៀតសង្ឃឹមអី ។

ឈុនលី៖ ចុះកាលគាត់ហៅហ្នឹងឆ្នាំណា?

ជីនី ៖ ឪពុកខ្ញុំមកកាលឆ្នាំថ្ងៃសម្ដេចនាយកយាងមក ។

ឈុនលី៖ ១៩៩៧ ហ្នឹងអ្វី?

ជីនី ៖ ចាំ! ហើយពេលខ្ញុំទៅឃើញគេទុកបាយឲ្យគាត់មួយចាន ចឹងនឹកឃើញខ្លាចចិត្តអាណិតគាត់ខ្ញុំ យក គាត់មកនៅនេះ ។ គាត់ស្លាប់ចំថ្ងៃសម្ដេចយាងមក តែគាត់នៅជាមួយខ្ញុំបាន២ ៣ឆ្នាំដែរគាត់ចាស់ ហើយមុខឡើងបែកប្រជ្រុយ គាត់ទុំជ្រុះ ។

ឈុនលី៖ ចុះគ្រួសារមីងអាយុប៉ុន្មានហើយ?

ជីនី ៖ ឆ្នាំថោះ ៥៥ ៥៦ គាត់ធ្វើទាហានការពារព្រំដែនស្រុក ។

ឈុនលី៖ កាលពីមុនអ្វីមីង?

ជីនី ៖ តាំងពីមុនរហូតមករហូតនៅស្រុកម៉ាឡៃយើងនេះ ។
កាលពីមុនគេឲ្យទៅប្រាសាទតាមាន់អីនោះ ។

ឈុនលីៈ អ្ហ! កាលរឹកព្រះវិហារហ្នឹងអ្ហី?

ជីនី ៖ ចា៎! ព្រះវិហារហ្នឹងតែឥឡូវគេចង់បានតែក្មេងៗ ហើយចាស់ៗគេឲ្យបកមកចាំមើលកន្លែងនៅ បន្ទាយវិញ ។ ដឹកជញ្ជូនជាប់រហូតបាយស្អុកជាប់រហូត ។ កាលយើងជួបគ្នានៅសមរភូមិនៅតែសមរភូមិទេ ។
តស៊ូមកយូរហើយអាយុហាហុកសិបឆ្នាំហើយថាឲ្យកាត់ឈប់ធ្វើទ័ពនៅមិនឲ្យឈប់ អាងតែស្ងួតគេបេះតែប្រើ បើគេមានលុយកាត់បាន ។ ដូចខ្ញុំការងារភូមិថាខ្ញុំហត់ណាស់សុំឈប់ អត់ធ្វើទេ ។

ឈុនលីៈ មីងប្រធានភូមិ?

ជីនី ៖ ចា៎!

ឈុនលីៈ ឃុំនេះមានប៉ុន្មានភូមិ?

ជីនី ៖ មាន៨ភូមិ ។ ភូមិវាលហាត់ ភូមិដូង ភូមិក្បាលស្ពាន ភូមិកណ្តាល ត្រសេកជ្រុំ ដំបូកវិល វត្ត ចាស់ ភូមិថ្មី ។

ឈុនលីៈ យើងនេះភូមិត្រសេកជ្រុំ?

ជីនី ៖ ចា៎!

ឈុនលីៈ ធ្វើមេភូមិឆ្នាំណាមីង?

ជីនី ៖ ខ្ញុំធ្វើតពីគេទេតាំងពីអាណត្តិទី២ ទី៣មក ។

ឈុនលីៈ ចឹងជាងដប់ឆ្នាំហើយ?

ជីនី ៖ ចា៎!

ឈុនលីៈ ចុះអ្នកណាធ្វើមេភូមិពីដំបូងមក?

ជីនី ៖ ឈ្មោះពូរ៉ុម ហៃ រ៉ុម ដល់ក្រោយមក សូ ជាតិ ចេញពី សូ ជាតិ បានខ្ញុំ ។

ឈុនលីៈ ឆ្នាំណាមីង?

ជីនី ៖ យើងមកពី៨៥មកពូរ៉ុមកាន់កាប់ ក្រោយមកខ្ញុំ មុនខ្ញុំមានយាយជាតិដែរតែដល់អាណត្តិចុងក្រោយ ពេលបោះឆ្នោតគេអត់ធ្វើមេឃុំឲ្យខ្ញុំធ្វើ ។

ឈុនលីៈ ចុះឃុំនេះអ្នកណាកាន់កាប់មុនគេ?

ជីនី ៖ ពូហៀប ។

ឈុនលី៖ ឈ្មោះអីហៀប?

ជីនី ៖ មិនដឹងអីទេដឹងតែ ហៀប ខ្ញុំស្គាល់គាត់ ដល់ចេញពី ហៀប ហ្នឹងមកបាន អ៊ំសុខ ឪម សុខ ។

ឈុនលី៖ ចុះចៅហ្វាយស្រុក?

ជីនី ៖ ចៅហ្វាយស្រុក ឈុន ប៊ុននី ។

ឈុនលី៖ តាំងពីឆ្នាំណា? ស្រុកនេះកើតមានពេលណា?

ជីនី ៖ តាំងពីពួកខ្ញុំមកពី៨៥វិញ ឥឡូវគេប្តូរចៅហ្វាយស្រុកហើយចូល ទេព ឃុនណាល់ ឈុន ប៊ុននីប្តូរ ទៅខាងថ្មពួក ។

ឈុនលី៖ ចឹងទេព ឃុនណាល់កាន់ឆ្នាំណា?

ជីនី ៖ ឆ្នាំសម្តេចនាយកយាងមកឆ្នាំ៩៨ ៩៧ ។

ឈុនលី៖ ចឹងនៅនេះចូលសមាហរណកម្មឆ្នាំណា?

ជីនី ៖ ឆ្នាំសម្តេចមកឆ្នាំ៩៦ ៩៧ហ្នឹងឯង ។

ឈុនលី៖ មីងអាចចាំមួយណាឲ្យដាក់ច្បាស់ទេ?

ជីនី ៖ ប្រហែល៩៦ ៩៧ ហ្នឹងពេលសម្តេចយាងមកគេចចាំគ្នាតែម្តង ។

ឈុនលី៖ ខាងយើងនេះអ្នកណាចេញមុខចចារ?

ជីនី ៖ សម្តេចយាងមកហ្នឹងមកជុំគ្នា មានខាងហ៊ុន សិនប៉ិច ខាងសម រង្ស៊ី មកផ្សះផ្សានៅទីនេះតែម្តង ។

ឈុនលី៖ តែខាងយើងនៅទិនេះអ្នកណាគេដែលទៅហ្នឹង?

ជីនី ៖ មានអ៊ំ ខៀវ សំផន អ៊ំ នួន ជាអីនេះឯងគាត់អ្នកតស៊ូនៅទីនេះ ។

ឈុនលី៖ ចឹងបានន័យថាពេលមីងមកនៅទីនេះដំបូងក្រោមការដឹកនាំរបស់ពួកគាត់?

ជីនី ៖ ចាំ!

ឈុនលី៖ អ្នកណាខ្លះទៅមីង?

ជីនី ៖ អ៊ំ នួន ជា

ឈុនលី៖ គាត់មានបែងចែកតំបន់គ្នាឬកាន់រួមគ្នា?

ជីនី ៖ រួមគ្នា ។

ឈុនលី៖ កាន់ម៉េចទៅបើរួមគ្នា?

ជីនី ៖ ខុបមាថាគេចែងខាងប៉ៃលិនផ្សេង
ខាងម៉ាឡៃផ្សេងតែដល់ពេលចុះមកគេរួមសហការគ្នាតែមួយ ។
ឈុនលីៈ ចុះមីងដឹងទេថាអ្នកណាដែលកាន់តែនៅម៉ាឡៃនេះ?
មីងថាពេលមកជួបសម្តេចហ្នឹងមានពីខាង សំឡូត ប៉ៃលិន ម៉ាឡៃមកដែរចឹងមានន័យថាមានមេដឹកនាំធំនៅតាមតំបន់មួយៗចឹងមីងដឹងអត់?
ជីនី ៖ កាលមុនអ៊ំ នួន ជាអីនៅនេះដែរ អៀង សារី អៀង ធីរិទ្ធ តែឥឡូវគាត់ទៅនៅឯណោះអស់ ហើយ ។
ឈុនលីៈ ប្តីប្រពន្ធគាត់កាន់នៅម៉ាឡៃ ចុះអ៊ំ នួនជា?
ជីនី ៖ គាត់នៅខាងនេះ ហើយខាងនោះមកសហការគ្នាទៅនេះបន្តិចនោះបន្តិចខាងប៉ៃលិន ។
ឈុនលីៈ ចុះខាងសំឡូតមីងដឹងអត់?
ជីនី ៖ អត់ដឹងទេនៅឆ្ងាយពេក ។
ឈុនលីៈ ចុះប្រជាជននៅនេះហៅគាត់អីចឹង?
ជីនី ៖ ចា៎! គេហៅអ៊ំចឹង អ៊ំភា គាត់អាចទៅនៅភ្នំពេញហើយ ។
ឈុនលីៈ អ៊ំភា ហ្នឹងអ្នកណាគេ?
ជីនី ៖ អ្នកតស៊ូដែរ មេខ្មែរក្រហម ។
ឈុនលីៈ ឈ្មោះគាត់អីគេ?
ជីនី ៖ ឈ្មោះហៅក្រៅគាត់អ៊ំភា ឈ្មោះអៀង ធីរិទ្ធ អៀង សារីប្តីប្រពន្ធគាត់ អ៊ំនួន ជា ។
ឈុនលីៈ ចុះមីងដែលឃើញគាត់អត់?
ជីនី ៖ ដែលតើរូបថតគាត់ខ្មែរក្រហម គេបើកឲ្យមើលគាត់ចាស់អស់ហើយអ៊ំខៀវ សំផនគាត់កាន់ខាងទ័ព
កាលខ្ញុំនៅក្មេងគាត់ធ្វើតំណាងរាស្ត្រស្អាតណាស់ឥឡូវគាត់ចាស់បែកប្រជ្រុយ ។
ឈុនលីៈ មីងឃើញពេលណា?
ជីនី ៖ មើលរូបថតគេបើកឲ្យមើលអង្គការដែលមកប្រជុំនៅវត្តថ្ងៃមុន ។
ឈុនលីៈ អ៎ូ! ខាងអង្គការពួកខ្ញុំដែរហ្នឹង?
ជីនី ៖ ចា៎! ឥឡូវគាត់ចាស់អស់ហើយប៉ែតជាងហើយ ។
ឈុនលីៈ ចុះកាលគាត់គ្រប់គ្រងនៅនេះម៉េចដែរ?
ជីនី ៖ អត់អីទេគាត់ជួយខុបត្ថម្ភកូនចៅហើយសម្តេចខស្បាយាងមកតាមផ្លូវនេះណាស់ ។

ឈុនលីៈ គាត់មកធ្វើអី?

ជីនី ៈ មកទាក់ទងសហទូត ឧបមាថាមានប្រទេសណាមកចឹងមកទីនេះថៃ ដប៉ុនអី ។

ឈុនលីៈ ចុះមីងដូចមេធំដែលគ្រប់គ្រងនៅនេះមានអៀង សារីចឹង ចុះមានអ្នកណាថ្នាក់ក្រោមទៀត?

ជីនី ៈ មានទេព ឃុនណាល់ ។

ឈុនលីៈ ទេព ឃុនណាល់ ហ្នឹងគាត់ក្រោយទៀត ចុះតាំងពី៧៩មកច្បាស់ជាមានអ្នកនៅក្រោមៗគាត់ទៀត?

ជីនី ៈ មានបន្តៗទៀតតែគេមិនចេញ

បើអ៊ំៗចេញទៅអស់ហើយយើងប្រៀបធៀបថាអត់មេកូនវារផារ

តែអត់មេហើយកូនវារហើយបើមានមេទៅចេះតែកក់ក្ដៅ

ហើយតែគេចាប់មេហើយគេគង់តែចាប់ កូនទេចឹងហើយគេចេះតែលាក់ការទៅដើម្បីតស៊ូ

កើតជាតិជាខ្មែររបស់យើង យើងត្រូវតែតាំង

ចិត្តឲ្យរឹងមាំតស៊ូកុំឲ្យសាសាន៍គេចេះតែចូលមក ។ ដូចទឹកដីអ្ហ៎!

បើយើងកុំកាន់ថៃវាមកយកខ្ទេច

បើគ្រាន់តែយើងចេញទៅគេនាំគ្នាមករើតវ៉ាន់ក្នុងភូមិអស់រលីងសូម្បីតែផ្ទះសំបែងគេមករើអស់ ។

ឈុនលីៈ ចា៎! ចុះពួកគាត់សព្វថ្ងៃរស់នៅស្រុកម៉ាឡៃយើងនេះដែរដែលមីងថាអត់ចេញមុខ?

ជីនី ៈ មានតើតែគាត់ជម្លៀសទៅនៅភ្នំពេញអស់ហើយ ។

ឈុនលីៈ មីងស្គាល់ឈ្មោះគាត់ទេ?

ជីនី ៈ ឈ្មោះអ៊ំ បុត្រ អ៊ំអីហ្នឹង ។

ឈុនលីៈ ឈ្មោះបុត្រ?

ជីនី ៈ ចា៎!

ឈុនលីៈ ត្រកូលអីគេទៅ?

ជីនី ៈ អត់ដឹងទេស្គាល់តែឈ្មោះ ។ កូនទៅរៀននៅភ្នំពេញបានដឹង ។

ឈុនលីៈ គ្នាច្រើនទេពួកគាត់ដែលនៅគ្រប់គ្រងហ្នឹងអត់ចេញឈ្មោះ?

ជីនី ៈ មានតែភូមិ និងឃុំហ្នឹងហើយដែលច្បាស់ៗជាងគេ

គ្រប់គ្រងកូនចៅគណបក្សរបស់យើងអត់មាន ទៅណាទេមានតែអ៊ំទេព

ឃុនណាល់ហ្នឹងហើយបន្តវេនទៀត ចៅហ្វាយស្រុក ។

ឈុនលីៈ ពីដើមគាត់អ្នកនៅសម័យតស៊ូជាមួយមីនដែរអ្វី?

ជីនី : ក្រោយមកហើយទេ

កាលពីមុនបានអ៊ំអស់ហ្នឹងឯងអ្នកតស៊ូពីមុនៗមកយើងរត់លូនអីបានគាត់អ្នក

ទំនាក់ទំនងអង្គការផ្សេងៗយកជំនួយមកឲ្យពួកយើង ។

ឈុនលីៈ អ៊ំបុត្រអីហ្នឹងអ្វី?

ជីនី : ចាំ!

ឈុនលីៈ ចុះអ៊ំឃុនណាល់ គាត់មកពេលណាដែរ?

ជីនី : អ៊ំទើបតែមកដែរ ទើបតែមកតំណាងនេះអាណត្តិទី១ ទី២នេះទេគាត់មកពីភ្នំពេញ ។

គាត់យក ប្រពន្ធរបស់អ៊ំ ប៉ុល ពត អ៊ំមាន ស៊ីតំណែងអ៊ំ ប៉ុល ពត ។

ឈុនលីៈ អ្ហ៊ំ! ចឹងបានន័យថាកាលពីមុនអ៊ំ ឃុនណាល់ហ្នឹងក៏គាត់ធំដែរបានទាក់ទងចឹងនោះ?

ជីនី : ចាំ! ធំដែរ ។

ឈុនលីៈ គាត់ធ្វើអីទៅមីងជីងអត់?

ជីនី : កាលពីមុនធ្វើនៅមន្ទីរក្នុងដែរតែគេមិនប្រាប់យើងទេ

ទើបតែឥឡូវគាត់ធ្វើចៅហ្វាយស្រុកម៉ាឡៃ នេះ ។

ឈុនលីៈ ចឹងគាត់មានទំនាក់ទំនងគ្នាល្អហើយបានគាត់ស្គាល់ដល់ថ្នាក់ហ្នឹង?

ជីនី : ចាំ!

ឈុនលីៈ ចុះមីងដូចកាលយើងមកនៅឆ្នាំ៧៩ខ្ញុំសុំសួរបកបន្តិច យើងធ្វើអីទៅ?

ជីនី : អត់ធ្វើអីទេ អង្គការចិញ្ចឹមយើង អត់ទាន់មានស្រែចំការអីទេ ទាល់តែយើងបកពី៨៥វិញ

ហើយ បានកាប់ចំការកាប់អី ។

ឈុនលីៈ ៨៥? ចុះកាលសម័យសង្គ្រាមខ្លាំងមុនពេលចចារ?

ជីនី : អត់ទាន់មានធ្វើអីទេទាល់តែមកពី៨៥វិញ បានចាប់ផ្តើមធ្វើស្រែចំការ ។

ឈុនលីៈ ចុះដូចនៅឆ្នាំ៨០ ៨១មីងថាទៅថៃ ទៅបានប៉ុន្មានឆ្នាំ?

ជីនី : ៨៣ ៨៤អីហ្នឹងយើងបកមកវិញ ។

ឈុនលីៈ ចុះពេលយើងមកហ្នឹងមានសង្គ្រាមបាញ់គ្នាដែរអត់?

ជីនី : អត់មានទេនៅនេះអស់ហើយយើងផ្សះផ្សាគ្នា ។

ឈុនលីៈ តែសុទ្ធតែមីនអ្វី?

ជីនី : នៅមានកាលពីមុនតែដល់ពេលថ្ងៃផ្សះផ្សាយើងបញ្ចប់អត់មានអីទៀតទេ ។

ឈុនលីៈ អត់ទេចង់និយាយថាពេលដែលយើងជម្លៀសទៅហ្នឹងគេចាប់ផ្តើមដាក់មីនអ្វី?

ជីនី ៖ ចា៎! វាយមីន ។

ឈុនលីៈ ចឹងមីនមិននៅសល់?

ជីនី ៖ ចា៎! នៅសល់តែយើងរាវរករហូតដល់ឥឡូវយើងមានដំណើរការជាមួយស៊ីម៉ាក់គេអាចជួយមក ដោះឲ្យប្រជាជនយើងមកធ្វើស្រែធ្វើលំនៅដ្ឋានបាន ។ បើយើងមកនៅដំបូងអត់មានអីយើងរាវដូច ថាសំរាប់ផ្ទះចឹងទៅណាស ហើយបើយើងមានលទ្ធភាពយើងធ្វើសំណើរឲ្យស៊ីម៉ាក់ជួយ ។

ឈុនលីៈ ចឹងបានន័យថាអត់ហ៊ានធ្វើដំណើរទៅណាឆ្ងាយទេ?

ជីនី ៖ អត់ទេ អត់ហ៊ានទៅទេសូម្បីតែឆ្លងទៅដីថៃជិតនេះ អ្នកដំណើរមកពីខ្មែរគ្នាឆ្លងទៅបត់ជើងផ្ទុះមីន ឆ្ងាយពោះស្លាប់ ។

ឈុនលីៈ ឆ្នាំណាមីង?

ជីនី ៖ ខ្ទង់ប៉ែតជាងហើយ ។

ឈុនលីៈ ចុះកាលនោះមានថៃឈ្លានពានលើដីយើងអត់?

ជីនី ៖ មាន ចូលមកផ្ទុះមីនស្លាប់អស់មិនចេះតិច ពេលយើងចេញទៅវាចូលអាថៃអស់នេះកុំថាល្អ ។

ឈុនលីៈ ពេលយើងទៅជំរុំហ្នឹងអ្វី?

ជីនី ៖ ចា៎! ជំរំជិតៗនេះ ។

ឈុនលីៈ មីងគេហៅជំរុំអីគេ?

ជីនី ៖ ជំរំ គេហៅ៨៥ ។

ឈុនលីៈ តំបន់៨៥ ឬជំរំ៨៥?

ជីនី ៖ ជំរំ៨៥ ហើយចេញពីហ្នឹងទៅបានទៅនៅជំរំតាង៉ុក ។

ឈុនលីៈ ចឹងនៅជំរំបានប៉ុន្មានឆ្នាំមីង?

ជីនី ៖ ជំរំមិនមែននៅមួយកន្លែងទេណា មុនដំបូងទៅនៅស្រះកែវឯណោះ ។

ឈុនលីៈ ស្រះកែវនៅឯណាវិញ?

ជីនី ៖ នៅដីថៃចូលទៅក្នុងវិញ ។

ឈុនលីៈ មីងទៅឆ្នាំណា?

ជីនី ៖ ទៅតាំងពី៧៩ ម្តងចេញទៅនេះហើយចេញទៅនោះទៀត ច្រើនដំណាក់ណាស់ពួកខ្ញុំ ។

ឈុនលីៈ តែមុនដំបូងនៅឯណា?

ជីនី ៈ មុនដំបូងមកនៅទីនេះមួយរយៈ

ហើយចេះតែរត់ទៅចំការចេកបានមួយរយៈចេញទៅស្រះកែវ ។

ឈុនលីៈ ចឹងចេញទៅស្រះកែវនៅឆ្នាំ៨០ ហើយ?

ជីនី ៈ ចា៎! ដល់ចេញពី៨៥មកនៅនេះមួយរយៈដល់ក្រោយមករត់ប្រជាប់ប្រកឹងខ្មែរ-ថៃ ។

តំបន់៨៥ នៅក្នុងដីថៃទៅនៅប្រហែលឆ្នាំ៨១ ៨២

អីហើយបានក្រោយមកទៅនៅភ្នំតាង៉ុកហើយបានមក នៅនេះ ។

ឈុនលីៈ ភ្នំតាង៉ុក?

ជីនី ៈ ចា៎! ភ្នំតាង៉ុកដីខ្មែរនៅជាប់ថៃទៅខាងចំការចេកជាប់ប៉ៃលិន ។

ឈុនលីៈ តាង៉ុកហ្នឹងនៅស្រុកអីគេមីង?

ជីនី ៈ នៅខាងកំរៀង ។

ឈុនលីៈ នៅទីនោះមុនដំបូងធ្វើអីគេទៅ?

ជីនី ៈ ទៅដំបូងនៅក្នុងជំរុំជាអគារគេបើកអង្ករឲ្យហូប

គេចិញ្ចឹមយើងបើកបាយធារឲ្យដូចនៅស្រះកែវ ដែរ ។

ឈុនលីៈ មីងពេលទៅនៅជំរំចឹងគេមានអ្នកគ្រប់គ្រងដែរអត់?

ជីនី ៈ អ្នកគ្រប់គ្រងមានតែអ៊ំៗហ្នឹងហើយដែលជួយទំនាក់ទំនងជាមួយកាកបាទអី ។

ឈុនលីៈ ចុះខាងខ្មែរយើងអ្នកណាដែលមើលការខុសត្រូវ

ធម្មតាពេលយើងទៅណាទៅណីតែងតែមានអ្នកដឹក នាំទៅជាមួយ?

ជីនី ៈ មានតើ គេរួមគ្នាតែម្តងគេរួមគ្នាចែកជាក្រុមៗតាមអគារមានថៃគេជួយមើលយើងដែរ

តែខ្ញុំមិន ចាំទេព្រោះអីគ្នារាប់សែននាក់អត់ចាំទេ ។

ដល់ពេលមាតុភូមិនិវត្តមកវិញមានតែអង្គការហ្នឹងហើយ

សួរយើងថាអ្នកណាស្ម័គ្រចិត្តមាតុភូមិនិវត្តទៅស្រុកទៅចំការវិញ ។

ខ្ញុំចុះឈ្មោះនឹងគេហើយម្នាក់ៗ

ឲ្យទៅសហរដ្ឋគ្រប់ៗគ្នាតែខ្ញុំមិនទៅទេខ្ញុំមានបងប្អូននៅទីនេះ ។

គេថាខ្ញុំទាគេឲ្យគេឲ្យឡើងខ្ពស់មុខមាត់ នឹងគេហើយអត់ទៅទៀត ។ ខ្ញុំថាអត់ទេ

ពុកម៉ែខ្ញុំនៅទីនេះសុខចិត្តមាតុភូមិនិវត្តមកស្រុកវិញហើយ អង្គការគេសើចថា

គេឲ្យទៅកន្លែងស្រួលហើយម៉េចមិនទៅ? ខ្ញុំថាអត់ទេសុខចិត្តស្លាប់រស់នៅស្រុក

កំណើតនេះហើយ ។ កូនៗខ្ញុំថា ម៉េចម៉ែអត់ទៅនឹងគេ? ខ្ញុំថាអត់ទេកូនអើយយើងមានកម្ម

បើ  យើងមកស្រុកវិញមានដីស្រែធ្វើចុះទៅនោះមានអី  ទៅនៅស្រុកគេស្មានតែស្រួលអ្វី សុខចិត្តមក នៅស្រុកឯងវិញ ។

ឈុនលីៈ ចុះមានគេទៅច្រើនទេមីង?

ជីនី ៈ មានច្រើនតើអ្នកគ្រូ ភាគច្រើនអ្នកនៅរោងចក្រជាមួយគ្នាអ្នកខ្លះគេរៀនចេះកាលពីមុនមកគេអាច ទៅបានរកការងារបានធ្វើបើយើងអត់ចេះអីទៅមិនដឹងធ្វើអីទេ ។

ឈុនលីៈ ចឹងមីងចូលស្រុកនេះឆ្នាំ៨៥?

ជីនី ៈ ចា៎!

ឈុនលីៈ ចឹងចូលមកចាប់ផ្តើមរានដីព្រៃអ្វី?

ជីនី ៈ ចា៎! មកដល់ចាប់ផ្តើមរុករានធ្វើលេណដ្ឋានខ្លួនឯងតែម្តងតាមគ្រួសារប្តីចូកខ្លួនឯង ។

ឈុនលីៈ ភ័យទេមីងចឹង?

ជីនី ៈ ភ័យ  ព្រៃខ្លាព្រៃរនាម ។ ខ្ញុំដែលឃើញជ្រូកព្រៃដែរ ។

ឈុនលីៈ មីងមានដឹងទេពេលចេញពីថៃមកមានប៉ុន្មាននាក់?

ជីនី ៈ អត់ចាំទេ  មានច្រើនហើយគេបែកទៅនៅតាមកងខ្លះទៅនៅខ្លាងរាប់ ចឹងបេងវាបែកគ្នាអស់ទៅ កាលពីមុននៅតាមកងៗ ។

ឈុនលីៈ ចឹងពេលមកនៅទីនេះទៅកាប់ព្រៃទៅរួមគ្នាឬយ៉ាងម៉េច?

ជីនី ៈ មេគ្រួសារមកធ្វើដល់ពេលរួចហើយបានទៅដឹកកូនចៅមកពី៨៥ ។

ឈុនលីៈ អ្នកណាគេអ្នកធ្វើមុនគេ?

ជីនី ៈ គ្រួសារយើងអ្នកធ្វើទ័ព ហើយទ័ពយើងនៅប្រចាំទីនេះ ។

ឈុនលីៈ ចឹងមានន័យថាប្តីៗមកធ្វើនៅទីនោះទៅ?

ជីនី ៈ ចា៎! នៅទីនោះដល់ពេលធ្វើហើយបាននាំគ្នាមកនៅ ។

ឈុនលីៈ រយៈពេលប៉ុន្មានបានធ្វើផ្ទះបាននៅ?

ជីនី ៈ យូរដែរប្រហែលពីរ បីខែបានធ្វើហើយមកនៅ ។

ឈុនលីៈ ចឹងបើយើងអត់មានមុខរបបបានអីហូបចុកទៅ?

ជីនី ៈ កាកបាទគេបើកឲ្យនៅផ្លូវគល់ស្ពាននេះ ។

ឈុនលីៈ ប្រហែលរយៈពេលប៉ុន្មានបានឈប់ទទួល?

ជីនី ៖ ទទួលតាំងពី៧៩រហូតដល់ពេលខ្ញុំមកពី៨៥ក៏ទទួលបានដែរទើបតែដប់ម្ភៃឆ្នាំនេះទេ ។ អានេះប្រៀប ធៀបថាពីមុនម៉ែឪមានអីចេះតែខបត្តម្ភកូនទៅ ដល់ពេលវាដុះដៃដុះជើងទៅគេប្រលែងឲ្យធ្វើស្រែ ចំការខ្លួនឯងហើយ ។

ឈុនលីៈ ចឹងបានន័យថាពេលធ្វើផ្ទះបានហើយនៅតែទទួលអំណោយទៀត?

ជីនី ៖ កាលពីនៅកូនខ្ទមតូចៗនៅតែដល់ពេលឥឡូវធំៗហើយអត់ទទួលទៀតទេ ។

ឈុនលីៈ ចុះមីងមកធ្វើផ្ទះធំនៅឆ្នាំណា?

ជីនី ៖ ខ្ញុំទើបតែនៅឆ្នាំ២០០៩នេះដែរ ខ្ញុំនៅកូនខ្ទមតូចជាងផ្ទះក្មួយនេះទៀតប្រក់ស័ង្កសីផ្ទះចាស់ខ្ញុំ ។

ឈុនលីៈ មីងខ្ញុំចង់បញ្ជាក់ថា ពេលយើងមកពី៨៥នាំគ្នាធ្វើខ្ទមនៅហើយយើងនៅខ្ទមបានប៉ុន្មានឆ្នាំបានធ្វើផ្ទះ នៅ ហើយទទួលអំណោយបានប៉ុន្មានឆ្នាំបានយើងចេះកាប់ដីកាប់អីធ្វើស្រែ?

ជីនី ៖ មកនៅបានបួនប្រាំឆ្នាំដែរ បានធ្វើផ្ទះសំបែងប្រក់ស្បូវអី ហើយបានគេនៅតែខបត្តម្ភប្រហែលបួន ដប់ឆ្នាំដែរបានគេឈប់ខបត្តម្ភ ។

ឈុនលីៈ ចឹងទើបតែឈប់ដែរហ្នឹង?

ជីនី ៖ ចាំ! ប្រហែលឆ្នាំ២០០១ ២០០២ នេះឯងបានឈប់យើងចេះដុះដៃដុះជើងហើយបានឪពុក ម្ដាយប្រលែង ។

ឈុនលីៈ ចុះបានខាងណាមកជួយដោះមីនអី?

ជីនី ៖ បានខាងស៊ីម៉ាក់ ។

ឈុនលីៈ តាំងពីឆ្នាំណាមីង?

ជីនី ៖ តាំងពី២០០៥ ។

មុនហ្នឹងធ្វើតែខ្លួនឯងអត់មានអង្គការណាមកទេរហូតដល់ឥឡូវវាលអស់មិនចេះ តិចទេ ស៊ីម៉ាក់មកដោះឲ្យសឹងតែរាល់ថ្ងៃដែរ ។

ឈុនលីៈ ចុះពួកស៊ីម៉ាក់មកធ្វើចឹងដែរមានបញ្ហាគ្រោះថ្នាក់អីដែរអត់?

ជីនី ៖ មាន ខ្លះដាច់ដៃដាច់ជើងចឹងទៅ ។

ឈុនលីៈ ចុះប្រជាជនដែលដោះមីនខ្លួនឯងមានគ្រោះថ្នាក់ដែរ?

ជីនី ៖ មាន ខ្លះកាប់ដីដាំចឹងទៅផ្ទុះពីងចឹងទៅ ខ្លះឈូសទៅផ្ទុះចឹងទៅ ។

ឈុនលីៈ ចុះមីងនៅភូមិនេះពិការច្រើនទេ?

ជីនី ៖ ច្រើនដែរប្រហែលដប់នាក់ដែរ ។ ផ្ទះនេះពិការជើង ហើយផ្ទះនេះពិការភ្នែក នេះប្ដីពិការដែរពិការ ច្រើនណាស់ ។

ឈុនលី៖ គាត់ដើរបានដែរ?

ជីនី ៖ បាន គាត់មួយកំណាត់ បើនោះគាត់ទាំងសងខាងទៅធ្វើស្រែនៅដំបូងវិល ។ នេះផ្ទះក្មួយខ្ញុំដែរគាត់ សងខាង ។

ឈុនលី៖ ទៅពេទ្យណាទៅមីង?

ជីនី ៖ យកទៅ៨៥ និងថ-១៥ពេទ្យដែលអីៗនៅ ។

ឈុនលី៖ ថ-១៥ហ្នឹងអីគេ?

ជីនី ៖ ថ-១៥នៅឯភ្នំដងរែក ។

ឈុនលី៖ មីងថាអីៗហ្នឹងអីណា?

ជីនី ៖ អ៊ំ ដុំ ជឿន (ដួន ជឿន) គាត់ដុកទ័រតែឥឡូវមិនដឹងគាត់ស្លាប់ឬនៅទេគាត់ដុកទ័រទៅរៀនទៅស្រុក ចិន ។

ឈុនលី៖ ចុះគាត់មកនេះយូរហើយនៅ?

ជីនី ៖ យូរហើយ ។

ឈុនលី៖ ជំនាន់ជាមួយមីងដែរអត់?

ជីនី ៖ ចាំ!

គាត់ធ្វើពេទ្យធំជាងគេបន្ទស់ព្យាបាលសូម្បីតែកូនបញ្ច្រាសម៉េចក៏ជួយបានដែរឲ្យតែពេលម៉ោង ៤ឡើងគាត់ចងមុងនៅក្នុងមុងហើយគាត់ខ្វាចឆ្លងគ្រុនចាញ់ ។

ឈុនលី៖ ចឹងពេទ្យហ្នឹងគាត់ជួយបងប្អូនយើងដែរ?

ជីនី ៖ ចាំ! គាត់ជួយមានកូនខ្លះកើតមកអត់មានលលាដ៍ក្បាល គាត់យកមកចិញ្ចឹមនៅក្នុងកែវឲ្យយើង មើល ។

ឈុនលី៖ ចុះនៅពេទ្យថ-៨៥(ខ-៨៥)អ្នកណាគេគ្រប់គ្រង?

ជីនី ៖ មានអ៊ំជឿន ហើយក្រោយមកទៀតមានមានអ៊ំ គេង នៅខាងថ-៨៥(ខ-៨៥)ហើយអ៊ំហៃអ៊ីនៅ តគ្នារហូត ។

ឈុនលី៖ អ៊ំជឿនហ្នឹង ដុកទ័រចុះមានអ្នកណាគេគ្រប់គ្រងធំលើហ្នឹងទៀត?

ជីនី :

មានតែគាត់ហ្នឹងហើយព្រោះមកពីស្រុកចិនហ្នឹងមានតែគាត់ទេធំជាងគេក្រោយមកបានម
វនតូហែ ។

ឈុនលីៈ ចឹងពី៧៩មានគាត់មកដែរ?

ជីនី : មកដែរ ។

ឈុនលីៈ ចុះរហូតដល់ឥឡូវមីងប្រកបរបបអីគេ?

ជីនី : ខ្ញុំដាំដំឡូង ដាំពោត បន្លែ ស្វាយ ដូងអីជុំវិញផ្ទះគ្រាន់តែលក់ចិញ្ចឹមជីវិតខ្លួនឯង ។

ឈុនលីៈ លក់នៅឯណាទៅ?

ជីនី : មានស្តង់ពោតកន្លែងអ៊ំ ណាល់
គាត់ដាំដែរហើយគាត់មានរោងចក្រពោតចំហុយឡពោតនៅផ្លូវទៅ ឃុំសន្តែ
ហើយគាត់មានកន្លែងដាក់ដំឡូបប៉ុនណាណីលក់ចេញទៅថៃ ។

ឈុនលីៈ ចឹងមីងយកទៅលក់ឲ្យគាត់?

ជីនី : ចា៎! ពេលបានយកទៅលក់នៅរោងចក្រ ។ អ្នកស្រុកនេះដាំដំឡូងដាំពោត
សណ្តែកបាយសណ្តែក សៀង ស្រូវ ។

ឈុនលីៈ យកទៅលក់ឲ្យថៃ?

ជីនី : ទេ ស្រូវមិនចាំបាច់លក់ឲ្យថៃទេ ថៃគេចូលមកទិញ
ពោតក៏ចឹងដែរគេចូលមកតាមច្រកតូចនេះមក នៅកន្លែងតង់ហ្នឹង
កន្លែងថៃគេដាក់តង់ហ្នឹងនៅរោងចក្រ៩៣ក៏មានដែរ ។

ឈុនលីៈ ចឹងអត់មានធ្វើស្រែទេ?

ជីនី : មានគេចុះទៅធ្វើនៅបឹងក្រសាក ។

ឈុនលីៈ ចុះមីងមានអត់?

ជីនី : មីងអត់មានទេ ទិញអង្ករគេហូបថៃក៏ទិញរបស់ខ្មែរក៏ទិញ ។

ឈុនលីៈ ចឹងនៅនេះប្រើតែរបស់ពីថៃមក?

ជីនី : របស់ថៃខ្លះខ្មែរខ្លះ បើយើងទៅស្វាយយើងទិញរបស់ខ្មែរ ។

ឈុនលីៈ ចុះបើយើងប្រៀបធៀបគុណភាពមួយណាល្អជាង?

ជីនី : បើអង្ករមិនលើលគ្នាប៉ុន្មានទេ តែថៃគេចំរាញ់បានស្អាតជាងរបស់យើង ។
អង្ករយើងកិនមកមាន

ស្រូវអីខ្លះ ។

ឈុនលីៈ ចុះបន្លែបន្ទុកអី?

ជីនី ៖ បន្លែយើងដាំបានខ្លួនយើងមួយចំនួន

អ្នកខ្លះអត់ចាប់អារម្មណ៍ទៅទិញគេទាំងស្រុងតាំងពីដីខ្ទីមម្ទេស

បើខ្ញុំអត់ទេស្អីក៏មានពោតក៏មាន ។

ឈុនលីៈ ចុះក្មេងៗជំទង់ទៅធ្វើការនៅស្រុកថៃអ្វី?

ជីនី ៖ ចាំ!

ឈុនលីៈ ភាគច្រើនអ្វី?

ជីនី ៖ យើងនៅនេះមួយចំនួនទេភាគច្រើនអ្នកមកពីក្នុងដូចជាខាងបាត់ដំបង សៀមរាបកំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបងអីហ្នឹងរត់មករកថៃ ។

ឈុនលីៈ ទៅថៃធ្វើការអីខ្លះទៅមីង?

ជីនី ៖ ខ្លះទៅសំណង់ ខ្លះទៀតទៅថែបន្លែផ្លែឈើ ចិញ្ចឹមមាន់ បង្កង ជ្រូកទៅតាមមុខសញ្ញាគេ ។

ឈុនលីៈ បានប្រាក់ខែប៉ុន្មានមីង?

ជីនី ៖ ខាងសំណង់បានមួយថ្ងៃមួយរយដាង មួយរយហា មួយរយសែ មួយរយសាម មួយរយម្ភៃអី ហ្នឹងក្មេងស្រីៗ ។

ឈុនលីៈ អ្នកដែលទៅប្រុសឬក៏ស្រី?

ជីនី ៖ ទាំងប្រុសទាំងស្រីទាំងតូចទាំងធំ ។

ភូមិនេះមានភាគតិចទេដែលទៅភាគច្រើនអ្នកមកពីចំងាយ ។ អ្នកខ្លះធ្វើស្រែអត់បានមានភូមិខ្លះអត់មានភ្លៀងសោះ ។

ឈុនលីៈ ពេលខ្ញុំមកឃើញឡានគេដឹកមនុស្សច្រើនទៅណាទៅ?

ជីនី ៖ ទៅថៃ ខ្លះមកពីច្រូតសណ្តែកសៀង ដល់ខែគេច្រូតសណ្តែកសៀងហើយនេះ ។

ឈុនលីៈ របស់ខ្មែរតើអ្វី?

ជីនី ៖ របស់ខ្មែរ ។

ឈុនលីៈ ចុះថៃមានដីនៅហ្នឹងដែរអត់?

ជីនី ៖ ថៃមាន ពីមុនគេទំនាក់ទំនងតាមច្រកដឹងប្រជាជនពីនេះទៅ ហើយបើទៅច្រូតអីជិះកង់ទៅបានតែ ឥឡូវអត់មានទេ អ្នកស្រុកយើងទៅរកការងារដេកនៅនោះរកការងារខ្លួនឯង ។

ឈុនលីៈ ចុះកាលមីងមកនៅនេះពេលចេញពី៨៥មានថៃមកនៅលើដីយើងអត់?

ជីនី ៖ ចូលមកតែគេមានច្បាប់
ទិញសំបុត្រមកយើងហើយមុននឹងមកគេទាក់ទងទាហានដែលនៅព្រំដែន
បើត្រូវឲ្យមកបានឲ្យមក ។

ឈុនលីៈ ពេលមីងចូលបដិវត្តិមានដូរឈ្មោះអីដែរ?

ជីនី ៖ កាលពីមុនខ្ញុំឈ្មោះ យី ដល់ពេលឥឡូវឈ្មោះគង់ជីនី
តែឈ្មោះនោះហៅយូរហើយតែដល់ពេល បដិវត្តិដាក់ឈ្មោះជីនីមករហូត
បើអ្នកផ្ទះគេហៅឈ្មោះឃួនព្រោះខ្ញុំកាច ។

ឈុនលីៈ ខ្ញុំឮថាមានការបាញ់គ្នាមុនពេលចចារ?

ជីនី ៖ ចាំ!

ឈុនលីៈ កាលនោះមីងនៅឯណា?

ជីនី ៖ ខ្ញុំនៅហ្នឹងប្ដីក៏នៅតែប្រុងប្រៀបវេចបង្វិចហើយស្រេចម៉េចៗទៅនៅមាត់អូរ ។
មកកាលនោះខាង ប៉ៃលិនក៏មកជុំជាមួយយើងនៅទីនេះស្រាប់ ។

ឈុនលីៈ ឆ្នាំណាកាលនោះ?

ជីនី ៖ អាឆ្នាំក្រោយគេបំផុតមុនយើងចចារបើមិនប៉ែតកៅ
តែប្រហែលជាប៉ែតទេមើលទៅបើកៅជាង
យើងកើតសមាហារណកម្មជាមួយសម្ដេចអស់ហើយ ។

ឈុនលីៈ អាហ្នឹង៩៦ ៩៧ទេតើ?

ជីនី ៖ ចាំ! ៩១ ៩២ទេដឹងអ្នកគ្រូ ។

ឈុនលីៈ ចុះបើគេសមាហារណកម្ម៩៦ ៩៧ហើយចឹងប្រហែល៩៥អីហើយ?

ជីនី ៖ ចាំ! ប្រហែល៩៤ ៩៥ ហ្នឹងហើយ ។

ឈុនលីៈ ចុះកាលនោះមានអ្នកគ្រប់គ្រងហើយនៅដូចជាចៅហ្វាយស្រុកអី?

ជីនី ៖ កាលនោះមានលោក ឈុន ប៊ុននី ។

ឈុនលីៈ ចុះចៅហ្វាយខេត្ត?

ជីនី ៖ រ៉ែន ស៊ុម ។

ឈុនលីៈ រ៉ែន ស៊ុម?

ជីនី ៖ ចាំ! ឥឡូវខាងផ្នែកសេដ្ឋកិច្ចទេដឹង ។

ឈុនលីៈ ចុះកាលគាត់ធ្វើហ្នឹងឆ្នាំណាទៅ? សមាហារណកម្មហើយនៅ?

ជីនី ៖ មកសមាហរណកម្មនេះឯង កាលនោះគាត់មកតាមយន្តហោះដែរចុះនៅភ្នំយាយសំ មកលេងនៅ បន្ទាយ ។

ឈុនលី៖ បន្ទាប់ពីមកនៅនេះ ហើយមីងដែលទៅលេងស្រុកកំណើតដែរអត់?

ជីនី ៖ បានទៅតែម្ដងគត់ពេលអ៊ុនតាក់មក ខ្ញុំទៅយកឪពុកខ្ញុំមកនៅនេះ ។

ឈុនលី៖ ទៅតែម្ដងទេ?

ជីនី ៖ តែម្ដងអូ៎! កាលមុនទៅម្ដងទៀតតែទៅលេងត្រឹមកូនទៅរៀននៅភ្នំពេញអត់បានទៅស្រុកទេ ហើយ ខ្ញុំទៅលេងលោកក្មួយខ្ញុំនៅវត្តលង្ការ ។

ឈុនលី៖ អត់បានទៅស្រុកទេចឹង?

ជីនី ៖ អត់ទេនឹកឃើញថាកំពុងតែធ្វើផ្ទះឯណោះអត់មានអ្នកណាធ្វើបាយទឹកកូនជាប់រៀន ។

ឈុនលី៖ ចុះម្ដាយមីង?

ជីនី ៖ ម្ដាយខ្ញុំស្លាប់ហើយ ឪពុកខ្ញុំក៏ស្លាប់អស់ហើយ ។

ឈុនលី៖ ស្លាប់ពេលណាទៅ?

ជីនី ៖ ម្ដាយខ្ញុំស្លាប់តាំងពីខ្ញុំនៅ៨៥ ឪពុកខ្ញុំស្លាប់ពេលសម្ដេចយាងមកនេះ ។

ឈុនលី៖ ចុះម្ដាយមីងបានទៅ៨៥ដែរអត់?

ជីនី ៖ ម្ដាយខ្ញុំអត់បានមកទេគាត់នៅស្អាង ព្រែកតូចគាត់ស្លាប់នៅនោះ បើឪពុកគាត់ស្លាប់នៅទីនេះចំពេល សម្ដេចយាងមកផ្សះផ្សាគ្នាចំថ្ងៃច័ន្ទ ។

ឈុនលី៖ ចឹងមីងទៅពេលអ៊ុនតាក់មក៩១ ៩២អ្ហី?

ជីនី ៖ ចា៎! ទៅយកគាត់មក ។

ឈុនលី៖ ទៅយកហ្នឹងម្ដាយស្លាប់បាត់ហើយហ្នឹង?

ជីនី ៖ ចា៎! ម្ដាយស្លាប់ហើយ នាំកូនបានទៅលេងម្ដងទៅដល់ឃើញជីវភាពបងប្អូនដាបពេកខ្ញុំថាម៉ែអើយ ខ្ញុំអត់នៅទេ ម្នាក់ៗកូនច្រើន៧ ៨មួយសំបុក ។

ឈុនលី៖ ចុះមីងមានកូនប៉ុន្មាន?

ជីនី ៖ បួន តែបានកូនចិញ្ចឹមមួយទៀត៥ ប្រុស២ ស្រី៣ ។

ឈុនលី៖ ចុះមីងចង់ទៅលេងស្រុកទៀតអត់?

ជីនី :

ចង់ដែរតែចាំមើលពេលទំនេរបានទៅលេងចាំមើលជីវភាពស្រួលបន្តិចវាយ៉ាប់ពេកប្រហែលជាចូលឆ្នាំ ឆ្នាំក្រោយបានទៅ ខ្មោចម៉ែខ្មោចតាអីនៅទីនោះទាំងអស់ ។

ឈុនលីៈ ចុះបងប្អូនអីអត់ដែលមកលេងទេ?

ជីនី : មានបងថ្លៃនិងបងបង្កើតខ្ញុំមកមួយ ក្មួយៗអីគេមកលេងសឹងរាល់ខែដែរហ្នឹងណាស គេមកលេងខ្ញុំ តែខ្ញុំអត់មានពេលទៅវរវល់ពេកកូនជាប់នៅរៀន ហើយអាមួយទៀតទៅរកស៊ីនៅថៃចិញ្ចឹមប្អូនអត់ មានពេលទំនេរ ។

ឈុនលីៈ ចុះមីងមានលេខទូរស័ព្ទខ្ញុំអាចទំនាក់ទំនងបានទេ?

ជីនី : លេខ ០១៧ ២៨១៣៦៣

ឈុនលីៈ អត់មានរូបថតចាស់ៗមីង?

ជីនី : អត់ចោលនៅអំពិលប្រាំដើមអស់ហើយ ។

ឈុនលីៈ អំពិលប្រាំដើមហ្នឹងអីគេ?

ជីនី : នៅភូមិបរិល ។

ឈុនលីៈ ចឹងកាលនោះស្នាក់នៅហ្នឹង?

ជីនី : ចា៎!

ឈុនលីៈ ពេលណាមីង?

ជីនី : ពេលខ្ញុំរត់ពីរោងចក្រមកទៅកំពង់ឆ្នាំ ហើយដើរពីព្រលានយន្តហោះបាត់ដំបង រួចបានមកនៅអំពិល ប្រាំដើមប្រហែលជិតកន្លះខែអីបានបែកចេញ ។

ឈុនលីៈ ចុះមីងយល់ពាក្យថាផ្សះផ្សាដែរទេ?

ជីនី : ធ្វើឲ្យត្រូវគ្នា ។

ឈុនលីៈ ចា៎! ចុះមីងយល់ថាបើយើងផ្សះផ្សា តើមួយណាប្រសើរជាងបើភាគីមួយនៅឆ្ងាយពីគ្នាហើយមួយ នៅជិតគ្នាតើមួយណាងាយជាង?

ជីនី : នៅជិតគ្នាទទួលពត៌មានលឿននៅឆ្ងាយវាយូរ ។

ឈុនលីៈ ចឹងបានន័យថាមនុស្សពីរនាក់ឈ្លោះគ្នានៅភូមិផ្សេងគ្នាងាយស្រួលផ្សះផ្សាគ្នាចឹងហ្អី?

ជីនី : យើងអាចហៅមកសំរួលគ្នាបាន ផ្សះផ្សាគ្នាបានជិតគ្នាក៏សំរួលគ្នាបាន ។

ឈុនលីៈ សំរួលម៉េចទៅ?

ជីនី :

តាមបែបប្រពៃណីនិយាយល្អទន់ភ្លន់ដាក់គ្នាយើងប្រាប់ឲ្យចេះបន្ទន់ចិត្តកុំឲ្យមានរើកាប់ចាក់គ្នា ។

ឈុនលី: ចុះបើយើងប្រៀបធៀបទៅសម័យសង្គ្រាមសម័យប៉ុន្មានឆ្នាំវិញ បើគាត់ចង់ផ្សះផ្សាគ្នាវិញយ៉ាងណា ដែរព្រោះវាយូរណាស់ហើយ?

ជីនី : អាយូរចឹងអាចអ្នកខ្លះគេនៅចងគំនុំដែរ កាលពីមុនខឹងណាសអ្នកគ្រូពេលគេថាអ្នកនេះខ្មែរក្រហម ខ្មែរគ្នាឯង តែដល់ពេលឥឡូវផ្សះផ្សាគ្នាឯងទៅ ព្រោះអត់ចង់កើតទេសង្គ្រាមវាឆ្អែតអស់ហើយ យើងខ្មែរគ្នាឯងត្រូវគ្នាទៅសាច់ឈាមឯងដដែលវាគ្មានន័យអីទេ ។

ឈុនលី: ចុះចំពោះមីងវិញចង់ផ្សះផ្សាជាមួយអ្នកផ្សេងទេ?

ជីនី : អ្នកដទៃក៏ចង់ព្រោះយើងនៅជិតគ្នាចឹងកបិនអីគេចេះតែយកមកដាក់ដែរហ្នឹង ។

ឈុនលី: កាលសង្គ្រាមមុនសមាហារណកម្មហ្នឹងមីងបាចូលរួមជួយខាងយើងដែរអត់?

ជីនី : ខ្ញុំទាហានខ្មែរក្រហមនៅតែខ្មែរក្រហម ហើយគេខាងនោះប៉ាវ៉ា ។

ឈុនលី: ចុះមីងចូលរួមនឹងគេដែរអត់ស្រីៗចឹង?

ជីនី : យើងនៅនេះនាំគ្នាបិតចំរ៉ូងការពារទីតាំងរបស់យើង ។

ឈុនលី: ចំរ៉ូងធ្វើពីអីទៅ?

ជីនី : ធ្វើពីឫស្សី ជីកដាក់នៅក្នុងដីអាចខ្លះគេមានគ្រាប់ដាក់នៅជុំវិញតែពេលភ័យរត់ចូលជាន់ចំរ៉ូង ។ ចំរ៉ូង ពីដើមមានតាំងពីអាជ័រឆក់ពិស ហើយគ្រាប់មីនគេអាចច្នៃដាក់រំសេវសាំងដាក់ចូលគ្នាផ្ទុះខ្លាំងណាស់ កាលនោះមានទាហានជីកស្នៀងជាប់មីនគោនផ្ទុះស្លាប់អស់ច្រើនរបួសច្រើនយកទៅពេទ្យ៨-៨៥(១-៨៥) ។

ឈុនលី: ចឹងមីងជួយបិតចំរ៉ូងដែរ?

ជីនី : ជួយ ប្ដីជីកជញ្ជូនបាយទៅហើយប្រពន្ធបិតចំរ៉ូងហើយពេលខ្លះជីកជញ្ជូនគ្រាប់ទៅ ។

ឈុនលី: មីងទៅដែរ?

ជីនី : អត់ទេ គេអ្នកជីក ។

ឈុនលី: មីងចឹងមីងថាខ្មែរនិងខ្មែរក្រហមបើចង់ផ្សះផ្សាគ្នាពិបាកមែនទេ?

ជីនី : ពិបាក នៅគប់គ្នាម្ដងៗដដែល ។

ឈុនលីៈ តែឥឡូវអត់ទេហ្អី?

ជីនី ៈ ឥឡូវអត់ទេ ។

ឈុនលីៈ ចុះបើមីងស្រមៃថាក្នុងពេលបច្ចុប្បន្នបើចង់ផ្សះផ្សាគ្នាយ៉ាងម៉េចវិញ?

ជីនី ៈ វាអាចមានខ្មែរខ្លះនៅអាក់អន់ចិត្តដែររឿងគណបក្សផង ។

ទឹកដីយើងនៅនេះកុំតែខ្មែរក្រហមមក

កុំអីគេយកអស់ហើយចឹងពួកខ្ញុំអត់ចេញទេតែចេញថៃយកអស់ហើយ ។

«ចប់»